# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប២៥ឆ្នាំនៃព្រះវិហារពោធិ៍ចិនតុង
# ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨

*កែប្រែចរិតធម្មជាតិរបស់យើង*

អត្ថបទទី១៖ យរ ៣៣,១៤-១៦
អត្ថបទទី២៖ ១ថស ៣,១២-៤,២
ដំណឹងល្អ៖ លក ២១,២៥-២៨.៣៤-៣៦

បងប្អូនជាទីស្រឡាញ់!

យើងដឹងថាព្រះវិហារនេះ ជាសញ្ញាសម្គាល់មួយយ៉ាងពិសេស នៅក្នុងបរិវេនព្រលានយន្តហោះ ក្នុងកន្លែងដែលមានរោងចក្រជាច្រើន ដែលយើងមានប្រជាជនច្រើនទៅៗ។ ជាឱកាសនឹកដល់គ្រីស្តបរិស័ទ ដែលបានបានចាប់ផ្ដើមព្រះសហគមន៍សារជាថ្មីកាលពី២៥ឆ្នាំមុន ជាមួយលោកអភិបាលអេមីល។ ២៥ឆ្នាំមុនអត់មានអគារនៅជុំវិញ នៅនេះដូចជាដីទទេ មានតែព្រលានយន្តហោះមួយ។ ខ្ញុំធ្វើទេសនាជាភាសាខ្មែរលើកទី១ គឺនៅព្រះសហគមន៍ពោចិនតុងចាស់ គឺនៅពេលព្រះយេស៊ូឡើងស្ថានបរមសុខ ក្នុងខែឧសភា ឆ្នាំ១៩៩៩។ ២៥ឆ្នាំកន្លងមក ពេលយើងមានលោកពុកទិន លោកពុកហ្វ្រង់ស្វ័រសាវីយ៉េ ហើយសព្វថ្ងៃនេះយើងមានលោកពុកតូនី។ ជាពេលវេលាយូរដែលបានជួយ ដើម្បីឲ្យព្រះសហគមន៍យើងមានគ្រូគង្វាល និងព្រះសហគមន៍យើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីប្រកាសដំណឹងល្អក្នុងបរិវេណហ្នឹង។ យើងជាពន្លឺមួយពិសេសដើម្បីបំភ្លឺបងប្អូនដែលសព្វថ្ងៃគាត់ស្នាក់នៅទីនេះយ៉ាងច្រើន មិនមែនកន្លែងដាច់ស្រយាល។ យើងឃើញកន្លែងមួយដែលមានរោងចក្រ ដែលមានកម្មករ កម្មការិនី ដែលមានប្រជាជន មានបុរីវីឡា មានផ្ទះថ្មីៗ ដែលមានអ្នកមាននៅជាមួយអ្នកក្រ ដែលមានភ្ញៀវអន្តរជាតិដែលធ្វើដំណើរចេញចូល។ យើងត្រូវការដឹងថា ព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់មួយ ដើម្បីណែនាំឲ្យជីវិត និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ស្ដាប់លឺ និងមើលឃើញដល់បងប្អូនឯទៀតៗ។

យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់២៥ឆ្នាំនៃព្រះសហគមន៍យើង អរព្រះគុណព្រះជាម្ចាស់សម្រាប់១២នាក់ដែលនឹងទទួលអគ្គសញ្ញាលាបថ្វាស។ អគ្គសញ្ញាលាបថ្វាសដែលនៅក្នុងឆ្នាំនេះ យើងមានជិត១០០នាក់នៅក្នុងភូមិភាគទាំងមូល។ យើងអបអរសាទរមួយទៀត ព្រោះយើងចូលទៅក្នុងរដូវអបអរសាទរ ដែលព្រះយេស៊ូកំពុងយាងមក និងសម្រាប់ព្រះសហគមន៍រដូវរង់ចាំ មិនមែនពេលវេលាដែលយើងពិបាកចិត្ត ឬគិតថាមនុស្សយើងពោរពេញដោយអំពើបាប តែជាពេលមួយដែលយើងរង់ចាំរួមជាមួយព្រះនាងម៉ារី ដោយសារម្ដាយដែលនៅទីនេះដឹងហើយ នៅពេលដែលដល់ខែទី៨នៅពេលមានផ្ទៃពោះ យើងចាប់ផ្ដើមភ័យផង អរផង សប្បាយផង ជា

ថ្ងៃដែលយើងនឹងឃើញបុត្របុត្រី មានមុខយ៉ាងម៉េច? នៅសល់តែមួយខែទៀត យើងបានឃើញ ដូច្នេះយើងសប្បាយចិត្តណាស់។ ពេលវេលានេះ ដូចព្រះនាងម៉ារីគឺនៅសល់១ខែទៀតឆ្លងទន្លេ ដើម្បីប្រទានព្រះយេស៊ូ ដល់ព្រះសហគមន៍របស់យើងទាំងអស់ ដើម្បីព្រះសហគមន៍របស់យើង ទទួលការសង្គ្រោះ ដូចយើងស្តាប់នៅក្នុងអត្ថបទទី១ "**ខ្ញុំសន្យាថា បន្តិចទៀតយើងមានស្តេចមួយ ដែលសុចរិត ដែលយាងមកយកចិត្តទុកដាក់យើង យាងមកណែនាំឲ្យយើងមានជីវិត ដើម្បីណែនាំឲ្យយើងមានសេចក្តីសុខ**"។ ដូច្នេះ ថ្ងៃនេះដែលជាថ្ងៃពិសេសបំផុត សម្រាប់ព្រះសហគមន៍ យើងត្រូវកែប្រែចិត្តគំនិតដើម្បីធ្វើដំណើរជាមួយនាងម៉ារី ជាមួយលោកយ៉ូសែប ដើម្បីរៀបចំខ្លួនទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។

ដូច្នេះនៅថ្ងៃនេះ យើងពោរពេញដោយអំណរសប្បាយ ដោយសារព្រះយេស៊ូកំពុងយាងមក។ ថ្ងៃនេះជាអាទិត្យទី១ ដែលតាមប្រពៃណីរបស់យើង គោរពជីវិតរបស់យើងដែលពោរពេញដោយសេចក្តីសង្ឃឹម ដោយសារយើងដឹងថាបន្តិចទៀត យើងជួបជុំគ្នាដើម្បីថ្វាយបង្គំកុមារយេស៊ូដែលប្រសូតមក។ អំបាញ់មិញ យើងមិនបានច្រៀងសិរីរុងរឿងរបស់ព្រះជាម្ចាស់ យើងចាំដើម្បីកោតសរសើរសិរីរុងរឿងព្រះជាម្ចាស់នៅយប់ព្រះយេស៊ូប្រសូត រួមជាមួយទេវទូតទាំងឡាយដែលបានប្រកាសដល់មនុស្សទាំងអស់ ព្រះយេស៊ូប្រសូតហើយ ការសង្គ្រោះយាងមកហើយ។ យើងពោរពេញដោយសេចក្តីសុខ សម្រាប់មនុស្សទាំងអស់នៅលើផែនដីនេះ។ នៅក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូមានព្រះបន្ទូលថា "**សូមមើលសញ្ញាសម្គាល់ ដែលណែនាំយើងយល់ថាព្រះយេស៊ូកំពុងយាងមក**"។ ហេតុនេះហើយ ព្រះយេស៊ូយាងមក ណែនាំឲ្យយើងរៀបចំចិត្តគំនិតដោយប្រុងស្មារតីជានិច្ច និងដោយអធិដ្ឋានជានិច្ច។ កុំឲ្យងងុយដេក កុំឲ្យយើងភ្លេចខ្លួន កុំឲ្យយើងវង្វេង ផ្ទុយទៅវិញឲ្យយើងប្រុងស្មារតី ឲ្យយើងភ្ញាក់ស្មារតី ដោយយកចិត្តអធិដ្ឋានជាមួយព្រះជាម្ចាស់ជានិច្ច ដើម្បីឲ្យយើងទទួលអាកប្បកិរិយាថ្មី។ យើងមានអាកប្បកិរិយា ឥរិយាបទ និងចរិតធម្មជាតិរបស់យើង ប៉ុន្តែសម្រាប់យើងដែលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ និងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាសសូមនឹកឃើញ **តើយើងត្រូវមានអាកប្បកិរិយាដូចម្តេច ដើម្បីទៅជាគ្រីស្តបរិស័ទដ៏ពេញលក្ខណ:?** ៤អាទិត្យដើម្បីភ្ញាក់ស្មារតី និងកែប្រែអាកប្បកិរិយា និងចរិតធម្មជាតិរបស់យើង គឺខ្ញុំមាន១០ចំណុចៈ

**ទី១ ឲ្យយើងយកចិត្តទុកដាក់ទៅលើព្រះជាម្ចាស់** នេះជាមូលដ្ឋាននៃអ្វីៗទាំងអស់។ មានន័យថាឲ្យយើងផ្ញើជីវិតរបស់យើងពិតមែន ទៅលើព្រះជាម្ចាស់និងជំនឿរបស់យើង ដោយដឹងថាយើងទុកចិត្តលើព្រះជាម្ចាស់ និងទីពឹងលើព្រះជាម្ចាស់ ដែលជាព្រះបិតា ដែលស្រឡាញ់ ការពារធ្វើដំណើរជាមួយយើង និងលើកទឹកចិត្តយើងជានិច្ច។

**ទី២ ឲ្យយើងយកចិត្តទុកដាក់ស្វែងរកព្រះជាម្ចាស់** ស្វែងរកវត្តមានរបស់ព្រះអង្គនៅក្នុងជីវិតរបស់បងប្អូនឯទៀតៗ។ កុំឲ្យយើងភ្លេច ពេលយើងជួបពួកគាត់បីដូចជាយើងបានជួបព្រះជាម្ចាស់ ជាពិសេសជួបអ្នកក្រីក្រនិងអ្នកជំងឺ មនុស្សតូចតាចបីដូចជាវត្តមានរបស់ព្រះយេស៊ូពិតមែន។ ឲ្យយើងត្រូវរកវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងដួងចិត្តរបស់យើង។ ពេលខ្លះយើងចង់រកព្រះជាម្ចាស់នៅឆ្ងាយពេក ប៉ុន្តែតាមពិតព្រះជាម្ចាស់មិនឆ្ងាយទេ ព្រះជាម្ចាស់នៅទីនេះ នៅក្នុងដួងចិត្តរបស់យើង។ ពីមួយថ្ងៃទៅមួយថ្ងៃ នៅពេលយើងភ្ញាក់ពីដេក ឲ្យយើងអធិដ្ឋានដូចនេះ **ឱព្រះអម្ចាស់អើយ ដែលគង់នៅក្នុងដួងចិត្តរបស់យើង ខ្ញុំសប្បាយចិត្តណាស់ សូមចូលក្នុងដួងចិត្តរបស់ខ្ញុំ ដើម្បីរកឃើញព្រះអង្គដែលគង់នៅតាំងពីដើមរៀងមក។**

**ទី៣ ឲ្យយើងមានចិត្តល្អដល់បងប្អូនឯទៀតៗ** កុំឲ្យចិត្តរបស់យើងទៅជាចង្អៀតចង្អល់។ នៅក្នុងការរង់ចាំនេះ **តើយើងធ្វើអ្វីខ្លះល្អសម្រាប់អ្នកដទៃ?** សូម្បីតែមួយចំណុច សូមទៅវិញគិត។ ខ្ញុំធ្វើអំពើល្អមួយសម្រាប់អ្នកដទៃ សម្រាប់បងប្អូន សម្រាប់អ្នកក្រីក្រម្នាក់នៅក្នុងរដូវរង់ចាំនេះ។ កុំចាំនៅ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតហួសពេលហើយ។ ដូច្នេះសូមគិតពិចារណា **តើខ្ញុំធ្វើអំពើល្អមួយដូចម្ដេច ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមានអំណរសប្បាយ?** ដោយសារខ្ញុំសុខចិត្តចែកអំណររបស់ខ្ញុំដែលកំពុងទន្ទឹងរង់ចាំព្រះយេស៊ូ និងពេលវេលារបស់ខ្ញុំ ដល់អ្នកដែលកំពុងខ្វះខាត ឬអ្នកដែលកំពុងរងទុក្ខលំបាក។

**ទី៤ ឲ្យយើងសម្រុះសម្រួលជាមួយបងប្អូនឯទៀតៗ** ប្រសិនបើយើងឈ្លោះគ្នាជាមួយគេ បើយើងមានរឿងអត់ល្អជាមួយគេ ប្រសិនបើយើងមានបញ្ហាណាមួយជាមួយគេ ប្រសិនបើយើងជំទាស់ជាមួយគេ។ នៅក្នុងរដូវរង់ចាំនេះ ឲ្យយើងសម្រុះសម្រួលជាមួយបងប្អូនឯទៀតៗ និងកុំភ្លេចសម្រុះសម្រួលជាមួយព្រះជាម្ចាស់ ដោយសារយើងត្រូវការលើកលែងទោសពីព្រះអង្គគ្រប់ពេលវេលា។ សម្រុះសម្រួលដើម្បីមានចិត្តបរិសុទ្ធទទួលស្វាគមន៍ដែលកំពុងយាងមក។

**ទី៥ ឲ្យយើងយកចិត្តទុកដាក់ធ្វើជាមនុស្សតែមួយ** ពេលយើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យយើងយកចិត្តទុកដាក់។ មិនមែនយើងស្ដាប់ សូមស្រឡាញ់គ្នាទៅវិញទៅមកនៅក្នុងវិហារ និងពេលយើងចេញពី វិហារយើងទៅជេរគេ។ កុំឲ្យយើងស្ដាប់ សូមឲ្យយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមកនៅក្នុងវិហារ ពេលចេញពីវិហារយើងទៅមើលងាយគេ និងនិយាយដើមគេ។ កុំឲ្យយើងស្ដាប់នៅក្នុងវិហារ សូមជួយបងប្អូនឯទៀតៗអស់ពីដួងចិត្ត នៅពេលយើងចេញពីវិហារយើងបិទភ្នែកបិទត្រចៀកបិទបេះដូង អត់ចេះមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ ឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងស្ដាប់នៅក្នុងវិហារ ទៅជាព្រះបន្ទូលដែលយើងអនុវត្តនៅក្នុងជីវិតរស់នៅរបស់យើងប្រចាំថ្ងៃ ដើម្បីទៅជាមនុស្សតែមួយ។

**ទី៦ ឲ្យយើងយកចិត្តទុកដាក់ស្រឡាញ់** ស្រឡាញ់ហើយស្រឡាញ់ទៀត កុំគិតថាយើងស្រឡាញ់ល្មមហើយ យើងមិនដែលស្រឡាញ់ល្មមទេ។ ឲ្យយើងចេះស្រឡាញ់បងប្អូនឯទៀតៗ និងស្រឡាញ់ព្រះជាម្ចាស់។ នេះជាធម្មវិន័យតែមួយគត់ គឺ «**សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**»។ សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូស្រឡាញ់យើងដែរនេះជាធម្មវិន័យចុងក្រោយរបស់ព្រះយេស៊ូ។

**ទី៧ ឲ្យយើងដឹងគុណដល់ព្រះជាម្ចាស់** មានន័យថា ឲ្យយើងចេះអរព្រះគុណព្រះជាម្ចាស់ជានិច្ច។ នៅពេលយើងចាប់ផ្ដើមអភិបូជានេះ ខ្ញុំថាថ្ងៃនេះយើងអបអរសាទរ២៥ឆ្នាំ និងប្អូន១២នាក់ដែលទទួលអគ្គសញ្ញា និងអបអរជូវរង់ចាំ។ ប៉ុន្តែជាពិសេស យើងអរព្រះគុណព្រះជាម្ចាស់ដែលប្រទានជីវិតដល់ព្រះសហគមន៍យើង។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់គ្រីស្តបរិស័ទទាំងអស់ដែលយកចិត្តទុកដាក់រៀបចំខ្លួន ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូ។ ជីវិតជាគ្រីស្តបរិស័ទមិនមែនជាជីវិតរអ៊ូរទាំនិយាយដើមគេ អន់ចិត្តជាមួយព្រះជាម្ចាស់ ខឹងនឹងគេនិងឯង ប៉ុន្តែជីវិតរបស់យើង គឺជាជីវិតដែលចេះតែអរព្រះគុណ ដោយមានចិត្តដឹងគុណព្រះជាម្ចាស់ប្រទានជីវិត។

**ទី៨ ឲ្យយើងហ៊ាននិយាយប្រកាសដំណឹងល្អ កុំឲ្យយើងខ្មាស់** យើងទៅប្រកាសដំណឹងល្អដូចគ្រីស្តទូត គេភ័យ គេខ្លាច ប៉ុន្តែពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក គេចេញតាមផ្លូវ និងគេប្រកាសដំណឹងល្អ។ ដូច្នេះសូមគិត **តើយើងត្រូវធ្វើយ៉ាងម៉េចដើម្បីនិយាយអំពីព្រះជាម្ចាស់? តើយើងត្រូវធ្វើយ៉ាងម៉េចផ្ដល់សក្ខីភាពដល់បងប្អូនឯទៀតៗ?** យើងរស់នៅក្នុងផ្ទះដែលមានរបងនៅខាងកើត ខាងលិច ខាងជើង ខាងត្បូង ហើយទ្វារមានតែមួយ ដូច្នេះទ្វារនេះ ឲ្យយើងបើកចំហរហើយយើងបើកទ្វារនៃដួងចិត្តរបស់យើង ដើម្បីចែករំលែកសក្ខីភាព។ យើងមិនមែនគ្រីស្តបរិស័ទសម្រាប់គ្នាយើង នៅក្នុងតែបរិវេនរបងរបស់យើង។ យើងជាគ្រីស្តបរិស័ទ សម្រាប់មនុស្សទាំងអស់។ យើងដឹងថា យើងត្រូវហាននិយាយអំពីព្រះយេស៊ូ ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ មិនទុកសម្រាប់គ្នាយើង ដើម្បីប្រកាសដំណឹងល្អថែមទៀត។

**ទី៩ ឲ្យយើងទៅជាពន្លឺ** ដែលបំភ្លឺមនុស្សលោក យើងទៅជាអំពូលពិសេសម្យ៉ាងដែរ ដោយសារណែនាំឲ្យគេចាប់អារម្មណ៍ យើងជាអំពូលមួយដែលគេមើលឃើញនាំឲ្យគេចាប់អារម្មណ៍។ ដូច្នេះ ជីវិតរបស់យើងណែនាំឲ្យគេចាប់អារម្មណ៍ អំពីសក្ខីភាពដែលយើងផ្ដល់ជាពន្លឺសម្រាប់អ្នកដទៃ និងប្រហែលសម្រាប់ពិភពលោកទាំងមូល។

**ទី១០ សូមអធិដ្ឋានជានិច្ច** ប្រសិនបើយើងមិនអធិដ្ឋាន យើងអត់មានបរិយាកាសរស់នៅក្នុងជីវិតរបស់ព្រះជាម្ចាស់។ ដូច្នេះអធិដ្ឋានជានិច្ច យើងចូលវិហារផង ប៉ុន្តែនៅក្នុងដួងចិត្តរបស់

យើង យើងដឹងថាពេលព្រឹកយើងជម្រាបសួរព្រះជាម្ចាស់ ពេលល្ងាចយើងជម្រាបលាព្រះជាម្ចាស់ ដោយដឹងថាព្រះអង្គធ្វើដំណើរជាមួយយើងពីព្រឹកដល់យប់ និងពីយប់ដល់ព្រឹក ដើម្បីណែនាំឲ្យយើងរស់នៅ ដូចព្រះនាងម៉ារីនៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។

យើងដឹងថាអាកប្បកិរិយា ចរិតធម្មជាតិរបស់យើង ភ្ជាប់ជាមួយជីវិតដែលយើងបានទទួលពីថ្ងៃជ្រមុជទឹក ដូចដែលប្អូនៗទទួលថ្ងៃនេះថែមទៀត តាមរបៀបព្រះវិញ្ញាណដ៏វិសុទ្ធដែលកំពុងយាងមកសព្វថ្ងៃនេះសម្រាប់ប្អូន១២នាក់ និងសម្រាប់យើងទាំងអស់។ យើងចូលក្នុងរដូវរង់ចាំដែលណែនាំឲ្យយើងមានកម្លាំងដ៏កំពូល ដើម្បីទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ ដូច្នេះយើងនៅស្ងៀមស្ងាត់ អរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត សម្រាប់ជីវិតដែលយើងទទួល សម្រាប់ផ្លូវដែលកំពុងបើកនៅខាងមុខយើង ដើម្បីរៀបចំចិត្តគំនិត ប្រុងស្មារតី ដោយអធិដ្ឋានជានិច្ច ទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។ អាម៉ែន៕